# ក្រសួងបរិស្ថាន

Ministry Of Environment

# ថវិកាពលរដ្ឋ

# ឆ្នាំ ២០២៦

Citizen Budget

Fiscal Year 2026



**អាសយដ្ឋាន៖** អគារមរតកតេជោ ដីឡូត៍លេខ៥០៣ ផ្លូវកៅស៊ូ អមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
**គេហទំព័រ** ៖ https://www.moe.gov.kh/

## ១-ចក្ខុវិស័យ

ធានាឱ្យបាននូវចីរភាពបរិស្ថាន និងសុក្រឹតកម្មបរិស្ថានកិច្ច ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងលើកកម្ពស់ការអភិវឌ្ឍបៃតង។

## ២-បេសកកម្ម

ក្រសួងបរិស្ថាន ត្រូវបានរាជរដ្ឋាភិបាលប្រគល់បេសកកម្មឱ្យដឹកនាំនិងគ្រប់គ្រងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព សម្រាប់ជាឧត្តមប្រយោជន៍យូរអង្វែងរបស់ប្រជាជនគ្រប់រូបនិងគ្រប់ជំនាន់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រសួងបរិស្ថាន បានកំណត់គោលបំណងគោលនយោបាយសម្រាប់អនុវត្តថវិកាកម្មវិធីគឺ «កិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍដោយចីរភាព»។ ទន្ទឹមនឹងនេះ ក្រសួងបរិស្ថាន ក៏បានដាក់ចេញនូវគោលនយោបាយចម្បងៗដូចតទៅ៖

-លើកកម្ពស់ការវិនិយោគបៃតង តាមរយៈការកសាង ហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត ផលិតកម្មវៃឆ្លាត ការដឹកជញ្ជូនបៃតង ការគ្រប់គ្រងសំរាមសំណល់រឹង រាវ ប្លាស្ទិក និងសំណល់គ្រោះថ្នាក់ ការគ្រប់គ្រងគុណភាពខ្យល់ ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ការពង្រីកលំហបៃតង និងគាំទ្រសេដ្ឋកិច្ចសហគមន៍មូលដ្ឋាន។

-ពង្រឹងក្របខ័ណ្ឌគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធនឹងបរិស្ថាន ទឹក ដី ខ្យល់ ជីវៈចម្រុះ ការប្រែប្រួលអាកាសធាតុ និងការទូតបៃតង។

-បន្តអភិវឌ្ឍស្ថាប័ន បង្កើនសមត្ថភាពមន្ត្រីជំនាញ និងចំណេះដឹងបច្ចេកទេស ទាំងការសិក្សាស្រាវជ្រាវ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍លើផ្នែកបរិស្ថាន ការអភិវឌ្ឍបៃតង សន្តិសុខទឹក ជីវៈចម្រុះ និងការប្រែប្រួលអាកាសធាតុ។

ដើម្បីសម្រេចនូវគោលបំណងគោលនយោបាយខាងលើ ក្រសួងបរិស្ថាន បានដាក់ចេញកម្មវិធីគាំទ្រចំនួន ៤ រួមមាន៖

**១-កម្មវិធីទី១៖** កិច្ចគាំពារបរិស្ថាន

**២-កម្មវិធីទី២៖** ការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន

**៣-កម្មវិធីទី៣៖** ការរៀបចំគោលនយោបាយ និងការអភិវឌ្ឍដោយចីរភាព

**៤-កម្មវិធីទី៤៖** ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ។

## ៣-គោលដៅសូចនាករលទ្ធផល ថវិកាកម្មវិធីឆ្នាំ ២០២៦

ដើម្បីសម្រេចបានជោគជ័យ ក្រសួងបរិស្ថានបានកំណត់សូចនាករគន្លឹះ និងគោលដៅសូចនាករ ព្រមទាំងក្របខ័ណ្ឌថវិកាឆ្នាំ២០២៦ សរុបចំនួន ១០៦ ០៩៨,០ លានរៀល ទៅតាមកម្មវិធីនីមួយៗដូចខាងក្រោម៖

### ១-កម្មវិធីទី១ ៖ កិច្ចគាំពារបរិស្ថាន

ដើម្បីវាស់វែងលទ្ធផលសម្រេចបាន កម្មវិធីទី១ បានបង្កើតសូចនាករគន្លឹះចំនួន៣ ដូចខាងក្រោម៖

| គោលបំណងកម្មវិធី | សូចនាករគន្លឹះ | គោលដៅសូចនាករ |
|---|---|---|
| **គោលបំណងកម្មវិធីទី១៖** ទប់ស្កាត់ និងកាត់បន្ថយការបំពុលបរិស្ថាន ដើម្បីរក្សាបាននូវគុណភាពបរិស្ថានស្អាត និងលើកកម្ពស់សុខភាពសាធារណៈ | **សូចនាករលទ្ធផលចុងក្រោយទី ១.ក៖** សន្ទស្សន៍គុណភាពទឹកមានកម្រិតល្អ | ៨០≥QWI<៩៥ |
| | **សូចនាករលទ្ធផលចុងក្រោយទី ១.ខ៖** ភាគរយនៃបរិមាណសំរាម សំណល់រឹងទីប្រជុំជន ដែលបានប្រមូល ធៀបនឹងបរិមាណសំរាមដែលបានបង្កើតប្រចាំឆ្នាំ | ៧០% |
| | **សូចនាករលទ្ធផលចុងក្រោយទី ១.គ៖** កំហាប់គុណភាពខ្យល់ (PM2.5) ស្ថិតក្នុងកម្រិតស្តង់ដា | PM២,៥ តូចជាង ២៥ $\mu g/m^3$ |



ដើម្បីសម្រេចបានកម្មវិធីទី១ មានតម្រូវការថវិកាដូចខាងក្រោម៖

***កម្មវិធីទី១** = ១៤ ៦០៨,៥ លានរៀល
-រដ្ឋបាលកណ្តាល = ១១ ៥៩៦,០ លានរៀល
-មន្ទីរបរិស្ថានរាជធានី ខេត្ត = ៣ ០១២,៥ លានរៀល

**កម្មវិធីទី១ ៖ កិច្ចគាំពារបរិស្ថាន**




*កម្មវិធីទី១ ថវិកាឆ្នាំ២០២៦ កើនឡើង ២២២,៨% ធៀបនឹងថវិកាឆ្នាំ២០២៥*

### ២-កម្មវិធីទី២ ៖ ការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន

ដើម្បីវាស់វែងលទ្ធផលសម្រេចបាន កម្មវិធីទី២ បានបង្កើតសូចនាករគន្លឹះចំនួន២ ដូចខាងក្រោម៖

| គោលបំណងកម្មវិធី | សូចនាករគន្លឹះ | គោលដៅសូចនាករ |
|---|---|---|
| **គោលបំណងកម្មវិធីទី២៖** ធានាប្រសិទ្ធភាពការគ្រប់គ្រង ការអភិរក្សជីវៈចម្រុះ និងការស្តារឡើងវិញនូវធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ និងការលើកកម្ពស់ជីវភាពប្រជាសហគមន៍មូលដ្ឋាន ដើម្បីជំរុញសហគមន៍អព្យាក្រឹត្យកាបូន | **សូចនាករលទ្ធផលចុងក្រោយទី ២.ក៖** ចំនួនតំបន់ការពារធម្មជាតិត្រូវបានកំណត់និងបែងចែកតំបន់គ្រប់គ្រង | ៤តំបន់ (៥/៥ជំហាន) |
| | **សូចនាករលទ្ធផលចុងក្រោយទី ២.ខ៖** ចំនួនសហគមន៍នៅក្នុងនិងក្បែរតំបន់ការពារធម្មជាតិ ដែលបានលើកកម្ពស់ជីវភាព | ៥សហគមន៍ |

ដើម្បីសម្រេចបានកម្មវិធីទី២ មានតម្រូវការថវិកាដូចខាងក្រោម៖

***កម្មវិធីទី២** = ៣៤ ៣៨២,២ លានរៀល
-រដ្ឋបាលកណ្តាល = ១១ ០៦០,០ លានរៀល
-មន្ទីរបរិស្ថានរាជធានី ខេត្ត = ២៣ ៣២២,២ លានរៀល

**កម្មវិធីទី២ ៖ ការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និង ការអភិវឌ្ឍសហគមន៍មូលដ្ឋាន**




*កម្មវិធីទី២ ថវិកាឆ្នាំ២០២៦ កើនឡើង ៣៩៨,០% ធៀបនឹងថវិកា២០២៥*

## ៣-កម្មវិធីទី៣ ៖ ការរៀបចំគោលនយោបាយ និងការអភិវឌ្ឍដោយចីរភាព

ដើម្បីវាស់វែងលទ្ធផលសម្រេចបាន កម្មវិធីទី៣ បានបង្កើតសូចនាករគន្លឹះចំនួន ៣ ដូចខាងក្រោម៖

| គោលបំណងកម្មវិធី | សូចនាករគន្លឹះ | គោលដៅសូចនាករ |
|---|---|---|
| **គោលបំណងកម្មវិធីទី៣៖** លើកកម្ពស់ និងចូលរួមរៀបចំការអនុវត្ត វាយតម្លៃគោលនយោបាយ យុទ្ធសាស្ត្រ ពាក់ព័ន្ធវិស័យបរិស្ថាន ព្រមទាំងពង្រឹងយន្តការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនឆ្ពោះទៅការអភិវឌ្ឍដោយចីរភាព | **សូចនាករលទ្ធផលចុងក្រោយទី ៣.ក៖** ចំនួនឃុំ/សង្កាត់ដែលបានបញ្ជ្រាបការងារបន្សាំ និងការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ ក្នុងផែនការវិនិយោគ ៣ឆ្នាំរំកិល | ១៧ឃុំ/សង្កាត់ |

ដើម្បីសម្រេចបានកម្មវិធីទី៣ មានតម្រូវការថវិកាដូចខាងក្រោម៖

***កម្មវិធីទី៣** = ៣ ៩០០,២ លានរៀល

-រដ្ឋបាលកណ្តាល = ៣ ៦៨៩,០ លានរៀល

-មន្ទីរបរិស្ថានរាជធានី ខេត្ត = ២១១,២ លានរៀល



**កម្មវិធីទី៣ ៖ ការរៀបចំគោលនយោបាយ និង ការអភិវឌ្ឍដោយចីរភាព**




*កម្មវិធីទី៣ ថវិកាឆ្នាំ២០២៦ កើនឡើង ១៧១,៧% ធៀបនឹងថវិកា២០២៥*

## ៤-កម្មវិធីទី៤៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ

ដើម្បីវាស់វែងលទ្ធផលសម្រេចបាន កម្មវិធីទី៤ បានបង្កើតសូចនាករគន្លឹះចំនួន ២ ដូចខាងក្រោម៖

| គោលបំណងកម្មវិធី | សូចនាករគន្លឹះ | គោលដៅសូចនាករ |
|---|---|---|
| **គោលបំណងកម្មវិធីទី៤៖** គាំទ្រដល់គ្រប់សកម្មភាពការងារ និងសេវានានា ក្នុងការធានា និងជំរុញឱ្យការអនុវត្តផែនការសកម្មភាពការងាររបស់ក្រសួងបរិស្ថានប្រកបដោយប្រសិទ្ធភាព និងការលើកកម្ពស់ចំណេះដឹងបរិស្ថានដល់សាធារណជន | **សូចនាករលទ្ធផលចុងក្រោយ ៤.ក៖** ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យផ្ទៃក្នុង | ត្រូវបានពង្រឹង |
| | **សូចនាករលទ្ធផលចុងក្រោយ ៤.ខ៖** ភាគរយនៃការអនុវត្តថវិកាធៀបនឹងច្បាប់ប្រចាំឆ្នាំ | ធំជាងឬស្មើ ៩៥ ភាគរយ ធៀបនឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ |

ដើម្បីសម្រេចបានកម្មវិធីទី៤ មានតម្រូវការថវិកាដូចខាងក្រោម៖

***កម្មវិធីទី៤** = ៥៣ ២០៧,១ លានរៀល

-រដ្ឋបាលកណ្តាល = ២៩ ៨៦១,០ លានរៀល

-មន្ទីរបរិស្ថានរាជធានី ខេត្ត = ២៣ ៣៤៦,១ លានរៀល



**កម្មវិធីទី៤៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ**




*កម្មវិធីទី៤ ថវិកាឆ្នាំ២០២៦ ថយចុះ -៤២,៥% ធៀបនឹងថវិកាឆ្នាំ២០២៥*